**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**កិច្ចព្រមព្រៀង**

**រវាង**

**ក្រុមហ៊ុន ខូបេស (ខេមបូឌា) ហ្វឺស ហ្គាម៉ិន ឯ.ក**

**ជាមួយប្រតិភូបុគ្គលិក តំណាងសហជីពមូលដ្ឋាន និងប្រធានក្រុមប្រចាំក្រុមហ៊ុន**

នៅថ្ងៃទី១៤ ខែសីហា ឆ្នាំ២០២៣ វេលាម៉ោង១៤:៣០នាទី ល្ងាច នៅក្នុងរោងចក្រ ខូបេស (ខេមបូឌា) ហ្វឺស ហ្គាម៉ិន មានកិច្ចប្រជុំមួយរវាងតំណាងក្រុមហ៊ុន ប្រតិភូបុគ្គលិក តំណាងសហជីពមូលដ្ឋាន និងប្រធានតាមក្រុម។ ក្នុងអង្គប្រជុំនេះ នាយកក្រុមហ៊ុនបានជូនដំណឹងដល់កម្មករនិយោជិតទាំងអស់ស្តីពីស្ថានភាព បច្ចុប្បន្ននៃក្រុមហ៊ុន ដែលខ្វះការបញ្ជាទិញពីអតិថិជន ។ហេតុដូចនេះ ក្រុមហ៊ុនសម្រេចចិត្តព្យួរកិច្ចសន្យាកាងាររបស់ កម្មករនិយោជិតចំនួន៣៨៩នាក់(ស្រី៣០៤នាក់)ក្នុងចំណោមកម្មករនិយោជិតសរុបចំនួន៣៨៩នាក់(ស្រី៣០៤នាក់)។ រយៈពេល៦១ថ្ងៃ ដោយគិតចាប់ពីថ្ងៃទី២១ ខែសីហា ឆ្នាំ២០២៣ ដល់ថ្ងៃទី២០ ខែតុលា ឆ្នាំ២០២៣។ ហើយក្នុងកំឡុងពេលព្យួរការងារនេះ កម្មករនិយោជិតបានឯកភាពទទួលការផ្តល់ជូនរបស់ក្រុមហ៊ុននូវប្រាក់ឧបត្ថម្ភ ជូនកម្មករនិយោជិតម្នាក់ ចំនួន៧៥ដុល្លា ក្នុងនោះ៖

-ចំនួន១៥ដុល្លា ពីថ្ងៃទី២១ដល់ថ្ងៃទី៣១ ខែសីហា

-ចំនួន៣០ដុល្លា ពីថ្ងៃទី១ ដល់ថ្ងៃទី៣០ ខែកញ្ញា

-ចំនួន៣០ដុល្លា ពីថ្ងៃទី១ ដល់ថ្ងៃទី២០ ខែតុលា

ប្រាក់ឧបត្ថម្ភក្នុងកំឡុងពេលព្យួរកិច្ចសន្យាការងារនេះនឹងបើកជូនបងប្អូនកម្មករនៅថ្ងៃទី១០នៃខែបន្ទាប់។ អង្គប្រជុំបានបញ្ចប់នៅវេលាម៉ោង១៥និង៣០នាទី ល្ងាច នាថ្ងៃខែឆ្នាំដដែល ប្រកបដោយបរិយាកាសរីករាយ និង ស្និតស្នាលក្រោមស្មារតីទទួលខុសត្រូវខ្ពស់ និងយោគយល់សហការគ្នាយ៉ាងរលូន។

ថ្ងៃចន្ទ ១៣រោច ខែទុតិយាសាឍ ឆ្នាំថោះ បញ្ចស័ក ពុទ្ធសករាជ ២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី១៤ ខែសីហា ឆ្នាំ២០២៣

តំណាងក្រុមហ៊ុន

ស្នាមមេដៃប្រតិភូបុគ្គលិក តំណាងសហជីពមូលដ្ឋាននិងប្រធានតាមក្រុម

ក្រុមហ៊ុន ខូបេស (ខេមបូឌា) ហ្វឺស ហ្គាម៉ិន ឯ.ក
COBEST (CAMBODIA) FIRST GARMENT CO., LTD
KINGDOM OF CAMBODIA

TANG W